# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤

## ជប៉ុនផ្តល់២០០,៣៣៩ ដុល្លាអាមេរិកសម្រាប់លើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជា

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន២០០,៣៣៩ដុល្លាអាមេរិក ដល់អង្គការសន្តិស្ម័គ្រចិត្ត (SVA) ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក តាម៉ារិ គីយ៉ូតាកា នាយកអង្គការSVA ដើម្បីអនុវត្ត"គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជាជំហានទីបី"។

ក្នុងគម្រោងនេះ អង្គការ SVA នឹងសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួនមួយខ្នង ដែលបំពាក់ទៅដោយគ្រឿងបរិក្ខារក្នុងឃុំតាអន ខេត្តសៀមរាប។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនជាង ៦៨,៣៦៨នាក់ក្នុងឃុំនេះ ដែលអាចបង្រៀនអោយចេះអាន និងសរសេរ ដើម្បីអនុវត្តជំនាញនៃការរស់នៅរបស់ពួកគេបាន។ លើសពីនេះ អង្គការSVA ក៏មានផែនការផ្តល់កម្មវិធីបង្កើនសមត្ថភាពដល់ក្រុមគ្រប់គ្រងការងារ និងបុគ្គលិករបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ សម្រាប់ការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្ថាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២៣លានដុល្លាអាមេរិក ដល់គម្រោងចំនួន៨២គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី២ តាមរយៈគ្រោងការណ៍នៃជំនួយនេះ សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៥ របស់ជប៉ុន(មេសា២០១៥ ដល់ មិនា ២០១៦)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*